**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ០០៧ សហវ.សរណន

រាជធានីភ្នំពេញ,ថ្ងៃទី០៣ខែធ្នូ ឆ្នាំ ២០០៣

# សារាចរណែនាំ

# ស្តីពី

# ការអនុវត្តន៍កិច្ចលទ្ធកម្មសាធារណៈ

ផ្អែកតាមបទពិសោធន៍ នៃបណ្តាឆ្នាំកន្លងមក ការដាក់អោយអនុវត្តនិតិវិធីដេញថ្លៃជាសាធារណៈ បានផ្តល់អោយរាជរដ្ឋាភិបាលនូវការសន្សំសំចៃថវិការដ្ឋបានមួយចំនួនធំ ហើយក្រសួង ស្ថាប័នរដ្ឋនានានៅតែអាច ទទួលបាននូវការផ្គត់ផ្គង់ទំនិញ និងសេវាជារូបវ័ន្ត ដូចការគ្រោងទុកពីដើមឆ្នាំ ។ ការទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កាគួរអោយកត់សំគាល់នេះ គឺអាស្រ័យដោយក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ ភាគច្រើនលើសលុបបានយកចិត្តទុកដាក់ខ្ពស់ អនុវត្តបានល្អតាមវិធីសាស្ត្រ និងនិតិវិធី លទ្ធកម្មសាធារណៈ ។ ទន្ទឹមនឹងនេះ ក៏នៅមានក្រសួង ស្ថាប័នមួយចំនួនមានការយឺតយ៉ាវ ពុំបានរួសរាន់អនុវត្តការប្រកាសដាក់អោយដេញថ្លៃដោយប្រកួតប្រជែង នៅដើមឆ្នាំ ឬ ដើមឆមាសនិមួយៗឡើយ ។ ឯកសារដេញថ្លៃនិងកិច្ចសន្យាលទ្ធកម្មមួយចំនួនត្រូវបានអូសបន្លាយរហូតដល់ត្រីមាសទី ៤ទើបចាប់ផ្តើមធ្វើហើយធ្វើហាក់ដូចជាប្រញាប់ប្រញាល់ខ្លាំងដើម្បីបង្ហើយបានមុនពេលដាច់ឆ្នាំ។ ការទូទាត់ត្រូវប្រមូលផ្តុំធ្វើនៅចុងឆ្នាំ នាំអោយចំណាយកើនឡើងយ៉ាងគំហុកដែលជាហេតុនាំអោយប៉ះពាល់ធ្ងន់ធ្ងរដល់តុល្យភាពសាច់ប្រាក់ ។

ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងចំណាយថវិការដ្ឋ កែលំអកាន់តែប្រសើរឡើងនូវអភិបាលកិច្ចល្អ សន្សំសំចៃឥណទាន បានកាន់តែច្រើនថែមទៀតសំដៅរួមចំណែកបំរើកម្មវិធីនយោបាយ និង កម្មវិធីកំណែទំរង់លើគ្រប់ផ្នែករបស់រាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមធ្វើការណែនាំអំពីការអនុវត្តន៍ កិច្ចលទ្ធកម្មសាធារណៈ ដូចតទៅ÷

១. គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ ចាប់ពីឆ្នាំ ២០០៤ ទៅត្រូវអនុវត្តអោយបានហ្មត់ចត់តាមនិតិវិធីដេញថ្លៃជាសាធារណៈសំរាប់ចំណាយក្នុងការទិញ សំភារៈ គ្រឿងចក្រ ឱសថ ស្បៀង សេវាជួសជុល សាងសង់គ្រប់ប្រភេទ ។

២. ដើម្បីធានាបាននូវភាពរលូននៃចំណាយថវិការដ្ឋ និងប្រសិទ្ធិភាពក្នុងការគ្រប់គ្រងសាច់ប្រាក់រួមទាំងមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើការងារលទ្ធកម្មសាធារណៈផងនោះ សាមីក្រសួង ស្ថាប័ន មន្ទីរ ជំនាញខេត្ត-ក្រុងនិមួយៗ ត្រូវរួសរាន់ប្រមូលផ្តុំគំរោង ស្នើសុំធានាចំណាយ សំរាប់មួយឆមាសម្តងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយបានត្រឹមថ្ងៃ២០ខែមករា សំរាប់ឆមាសទី១ និង ថ្ងៃ ២០ ខែ មេសា សំរាប់ឆមាសទី២ ។

៣. មិនអនុញ្ញាត អោយមានការសំរបសំរួលណាមួយដើម្បីបំបែក ឬអង្គន់គំរោងធានាចំណាយ អោយទៅជាគំរោងតូចៗ តំរូវតាមកំរិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិសំរេចក្នុងការអនុវត្តនីតិវិធីលទ្ធកម្មឡើយ ។ ករណីមានការបំបែក ឬ អង្គន់ធានាចំណាយលើមុខសញ្ញាតែមួយនោះ បុគ្គល ឬ ស្ថាប័ន សមត្ថកិច្ចត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

៤. ពេលលើកគំរោងសាម៉ីក្រសួង ស្ថាប័ន ខេត្ត ក្រុង សហគ្រាសសាធារណៈ ត្រូវពិនិត្យអោយបានច្បាស់លាស់នូវលក្ខណៈបច្ចេកទេស នៃមុខទំនិញនិមួយៗ ។ ករណីមានលាយឡំដោយទំនិញនាំចូលផ្តាច់មុខ ហើយ ធ្វើអោយប៉ះពាល់ដល់នីតិវិធីលទ្ធកម្មសាធារណៈ សាម៉ីក្រសួង ស្ថាប័ន ខេត្ត ក្រុង សហគ្រាសសាធារណៈ ត្រូវទទួលខុសត្រូវក្នុងការទទួលយកទំនិញផ្សេង ដែលមានលក្ខណៈបច្ចេកទេស គុណភាពប្រហាក់ប្រហែលគ្នា និងមានតំលៃសមស្រប បើពុំដូច្នោះទេ និងត្រូវចាត់ទុកជាមោឃៈ ហើយ មិនត្រូវបានជ្រើសរើសមកវាយតំលៃប្រគល់កិច្ចសន្យាឡើយ ។

៥.ទទួលបានគោលការណ៍ធានាចំណាយ អង្គភាពលទ្ធកម្ម ( PU )ត្រូវអនុវត្តតាមវិធីសាស្ត្រនិងនីតិវិធីលទ្ធកម្មសាធារណៈ ស្របតាមកម្មវិធីដែលមានចែងច្បាស់នូវរយៈពេលក្នុងដំណាក់កាល និមួយៗ នៃកិច្ចលទ្ធកម្ម ជាមូលដ្ឋានដូចខាងក្រោម÷

- -រៀបចំឯកសារដេញថ្លៃដោយប្រកួតប្រជែងជាសាធារណៈ (១សប្តាហ៍ យ៉ាងយូរ)
- -ផ្សព្វផ្សាយ និងលក់ឯកសារដេញថ្លៃ (២-៤ សប្តាហ៍ )
- -បើកឯកសារដេញថ្លៃ (១ ថ្ងៃ )
- -វាយតំលៃប្រគល់កិច្ចសន្យា (១ សប្តាហ៍ យ៉ាងយូរ)
- -រៀបចំ និងចុះកិច្ចសន្យា (១ សប្តាហ៍ យ៉ាងយូរ)

៦. សេចក្តីប្រកាសជូនដំណឹងស្តីពីការដេញថ្លៃ ត្រូវចុះផ្សាយអោយបានម្តង ឬ ពីរដងលើសារពត៌មានណាមួយក្នុងចំណោមសារពត៌មានបី ដែលកំពុងចរាចរទូលំទូលាយក្នុងព្រះរាជាណាចក្រកម្ពុជាគឺ រស្មីកម្ពុជា កោះសន្តិភាព និងកម្ពុជាថ្មី នៅផ្នែកខាងលើ នៃទំព័រផ្សាយពាណិជ្ជកម្មដែលមានទំហំ ១១សម X ១៥សម ។ ទន្ទឹមនឹងចុះផ្សាយតាមសារពត៌មាន អង្គភាពលទ្ធកម្មត្រូវបិទផ្សាយ ១ច្បាប់ នៅបញ្ជរផ្សព្វផ្សាយពត៌មានរបស់សាម៉ីក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈ និង ១ច្បាប់ទៀត នៅនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៧. ក្នុងរយៈពេលផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការដេញថ្លៃ អង្គភាពលទ្ធកម្មត្រូវចាត់តាំងមន្ត្រីម្នាក់អោយនៅ ប្រចាំការ រាល់ម៉ោងធ្វើការ ប្រយោជន៍ផ្តល់ពត៌មានដែលទាក់ទង នឹងការដេញថ្លៃ និង លក់ឯកសារដេញថ្លៃ ជូនអតិថិជនបានគ្រប់ពេលតាមការចង់បាន របស់អ្នកចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃត្រូវផលិតអោយបានគ្រប់គ្រាន់អាចឆ្លើយតបតាមតំរូវការ ហើយត្រូវលក់ ក្នុងតំលៃមួយសមស្របប្រហាក់ប្រហែលតំលៃដើមដែលបានផលិត ។

៨. សំណើដេញថ្លៃដែលបានបំពេញគ្រប់ជ្រុងជ្រោយហើយត្រូវដាក់ក្នុងស្រោមសំបុត្រ បិតអោយជិត ហើយ កាឡូងបញ្ជាក់ពីអាស័យដ្ឋានច្បាស់លាស់ព្រមទាំងបញ្ជាក់ថាមិនត្រូវបើកមើលមុនកាលបរិច្ឆេទត្រូវបើកឯកសារដេញថ្លៃ រួចដាក់ជូនអង្គភាពលទ្ធកម្ម តាមកាលបរិច្ឆេទដែលបានកំណត់ជាក់លាក់ ។ សំណើដេញថ្លៃណាដែលទទួលក្រោយ ឱសានវាទត្រូវចាត់ទុកជាមោឃៈ ។ ក្រោយឱសានវាទការកែតំរូវរាល់កំហុសឆ្គងក្នុងសំណើដេញថ្លៃមិនត្រូវបាន អនុញ្ញាតឡើយ ។

៩. តំលៃសរុបនៃកិច្ចសន្យាលទ្ធកម្មមិនអនុញ្ញាត អោយលើសពីឥណទានថវិកាដែលបានផ្តល់ធានាហិរញ្ញប្បទាន ឬ ចំនួនទឹកប្រាក់ដែលបានយល់ព្រមផ្តល់មុនបណ្តោះអាសន្នតាមអាណត្តិបើកប្រាក់ឡើយ ។

១០. មិនអនុញ្ញាតអោយមានការខ្ចីសំភារៈប្រើប្រាស់មុនឡើយ ។ ក្នុងករណីមានខ្ចីសំភារៈប្រើប្រាស់មុន ឬ ធ្វើការប្រគល់ទទួល (ទំនិញ-សំណង់) ដោយគ្មានកិច្ចសន្យាលទ្ធកម្ម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹង មិនទទួលខុស ត្រូវក្នុងការទូទាត់ជូនឡើយ ហើយសាមីក្រសួង ស្ថាប័ន ខេត្ត ក្រុង សហគ្រាសសាធារណៈ ត្រូវទទួលខុសត្រូវ នូវរាល់បាតុភាពដែលនឹងកើតឡើង ជាយថាហេតុ ។ កិច្ចសន្យាលទ្ធកម្មជាមូលដ្ឋានសំខាន់ និងចាំបាច់បំផុតសំរាប់ ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ លក្ខណៈបច្ចេកទេស គុណភាព តំលៃ រយៈពេលផ្គត់ផ្គង់ ឬសាងសង់ ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ។

១១.ការប្តូរបញ្ជីឈ្មោះតំលៃ ឬលក្ខណៈបច្ចេកទេស (ទំនិញ-សំណង់) ត្រូវបានហាមឃាត់ ។ ក្នុងករណីចាំបាច់ ដែលតំរូវអោយមានការពន្យាពេលអនុវត្តកិច្ចសន្យា ឬ តំរូវអោយមានការផ្លាស់ប្តូរបញ្ជីឈ្មោះតំលៃ ឬលក្ខណៈ បច្ចេកទេស (ទំនិញ-សំណង់) ខុសពីឧបសម្ព័ន្ធ នៃកិច្ចសន្យា ត្រូវតែមានការឯកភាព ជាលាយល័ក្ខអក្សរ របស់ ភាគីទាំងពីរ និងមានការយល់ព្រមចុងក្រោយពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

១២. ចំពោះការងារដែលទទួលអនុវត្ត ដោយអង្គភាពរដ្ឋ ត្រូវរក្សាទឹកប្រាក់ចំនួន 10% នៃតំលៃសរុប របស់កិច្ចសន្យាទុកជាការធានាគុណភាពជំនួសប្រាក់កក់ធានាគុណភាព រហូតដល់ផុតរយៈពេលធានាគុណភាពទើប ធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា ។

១៣. ក្រុមហ៊ុនដែលទទួលបានជ័យជំនះក្នុងការដេញថ្លៃ ជាសាធារណៈត្រូវទទួលចុះកិច្ចសន្យា ផ្គត់ផ្គង់ ឬ ជួសជុល ឬ សាងសង់តាមតំលៃដែលខ្លួនបានដាក់ដេញ ។ ក្នុងករណីមិនព្រមចុះកិច្ចសន្យា ក្រុមហ៊ុននោះ ត្រូវទទួលខាតបង់ប្រាក់កក់ធានាការដេញថ្លៃមិនតិចជាង ២% នៃតំលៃដាក់ដេញសរុបរបស់ខ្លួន ហើយនឹង ត្រូវបាត់សិទ្ធិចូលរួមដេញថ្លៃជាសាធារណៈ នៅគ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និងសហគ្រាសសាធារណៈ ក្នុងរយៈពេលមួយឆ្នាំ ។

១៤. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ កំណត់ថ្ងៃ ១៥ ខែវិច្ឆិកា រៀងរាល់ឆ្នាំជាថ្ងៃចុងក្រោយនៃការឈប់ទទួល ពិនិត្យសំណើឯកសារដេញថ្លៃគ្រប់ប្រភេទ ។

១៥. ប្រាក់កក់ធានាការដេញថ្លៃ

-ក្នុងការដាក់ "សំណើដេញថ្លៃ" ក្រុមហ៊ុនត្រូវកក់ប្រាក់ដែលហៅថា "ប្រាក់កក់ធានាការដេញថ្លៃ" ដែលមានទឹកប្រាក់ចំនួនយ៉ាងតិចស្មើ ២% (ពីរភាគរយ) នៃ "តម្លៃដាក់ដេញ" របស់ខ្លួន ។

-ប្រាក់កក់ធានាការដេញថ្លៃនេះក្រុមហ៊ុនត្រូវយកទៅកក់ខ្លួនឯងផ្ទាល់នៅ:

• រតនាគារជាតិ/ខេត្ត-ក្រុង ឬនៅសាខា ធនាគារជាតិខេត្ត-ក្រុង

• ឬគណនីប្រាក់កក់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា

• ឬនៅអង្គភាពលទ្ធកម្មដែលមាន PEAC រួមចំណែកទទួលខុសត្រូវ

-អង្គភាពដែលជាសមត្ថកិច្ច ទទួលប្រាក់កក់នេះ ត្រូវចេញលិខិតធានាមួយចំពោះមុខ សាមីក្រសួង ស្ថាប័ន ខេត្ត-ក្រុង សហគ្រាសសាធារណៈដែលមានឈ្មោះថា "លិខិតប្រាក់កក់ធានាការដេញថ្លៃ (មានទំរង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ។

-អង្គភាពដែលជាសមត្ថកិច្ច ពេលទទួលប្រាក់កក់នេះ មិនមានសិទ្ធិដេញដោយលចង់ដឹងពីតំលៃដាក់ដេញទេ ។

-ពេលបើកឯកសារដេញថ្លៃ ប្រសិនបើសំណើដេញថ្លៃណាបំពេញប្រាក់កក់ធានាការដេញថ្លៃមិនបានត្រឹមត្រូវនោះ នឹងត្រូវចាត់ទុកជាមោឃៈ ឬមិនត្រូវបានជ្រើសរើសមកវាយតំលៃប្រគល់កិច្ចសន្យាឡើយ ។

១៦. ប្រាក់កក់ធានាការអនុវត្តន៍

-ដើម្បីធានាការគោរពក្នុងការអនុវត្តន៍កិច្ចសន្យាអោយប្រព្រឹត្តទៅបានត្រឹមត្រូវ ក្រុមហ៊ុន ភាគី "អ្នកទទួលការ"/ភាគី "អ្នកផ្គត់ផ្គង់" ត្រូវមានប្រាក់កក់ដើម្បីធានា ហៅថា "ប្រាក់កក់ធានាការអនុវត្តន៍" ដែលមានចំនួនទឹកប្រាក់ស្មើ ១០% (ដប់ភាគរយ) នៃតម្លៃដាក់ដេញឈ្នះ (ហៅថាតម្លៃកិច្ចសន្យា) ។

-ភាគី "អ្នកទទួលការ"/ភាគី "អ្នកផ្គត់ផ្គង់" ត្រូវយកទៅកក់ដោយខ្លួនឯងផ្ទាល់នៅរតនាគារជាតិ/ខេត្ត-ក្រុង ឬសាខាធនាគារជាតិខេត្ត-ក្រុង ឬនៅគណនីប្រាក់កក់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា ។

-រតនាគារ ឬ ធនាគារពេលទទួលប្រាក់កក់គ្រប់ចំនួន ១០% (ដប់ភាគរយ) នៃតម្លៃកិច្ចសន្យាហើយ ត្រូវចេញលិខិតធានារក្សាប្រាក់កក់នេះដែលមានឈ្មោះថា "លិខិតប្រាក់កក់ធានាការអនុវត្តន៍" (មានទំរង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) ប្រគល់ជូនទៅភាគី "អ្នកម្ចាស់ការ"/ភាគី "អ្នកទិញ" តាមរយៈពេលកំណត់ក្នុងកិច្ចសន្យា ។

-អ្នកម្ចាស់ការ / អ្នកទិញ ត្រូវយកលិខិតធានាប្រាក់កក់មកនាយកដ្ឋានលទ្ធកម្មសាធារណៈ ១៥ថ្ងៃ យ៉ាងយូរ ក្រោយកិច្ចសន្យាចូលជាធរមាន ។ ក្នុងករណីយឺតយ៉ាវ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងពិនិត្យលុបកិច្ចសន្យា ។

នៅពេលទទួលបានសារាចរណែនាំនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សង្ឃឹមថា គ្រប់ក្រសួង-ស្ថាប័ន ខេត្ត-ក្រុង និង សហគ្រាសសាធារណៈ នឹងយកចិត្តទុកដាក់អនុវត្តសារាចរណែនាំនេះប្រកបដោយលទ្ធផលល្អប្រសើរ និង មានប្រសិទ្ធិភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់ខេត្ត-ក្រុង
-គ្រប់សហគ្រាសសាធារណៈ
-គ្រប់នាយកដ្ឋានពាក់ព័ន្ធក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ឯកសារ-កាលប្បវត្តិ